គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី

Active People's Microfinance Institution Plc.

# របាយការណ៍ប្រចាំឆ្នាំ
# ២០១៩



# 2019
## ANNUAL REPORT

Download AP Mobile

015 535 800 / 071 312 8777 / 011 324 474

www.apmfi.com.kh /ActivePeopleMFI

គ្រឹះស្ថានឯកជន / Private Company

# មាតិកា


➤ ប្រវត្តិសង្ខេប ទស្សនៈវិស័យ បេសកកម្ម ពាក្យស្លោក គោលការណ៍ណែនាំ និង ក្រុមអនុវត្តន៍របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី.....១

➤ របាយការណ៍ប្រចាំឆ្នាំ ២០១៩ សារពីនាយកប្រតិបត្តិ.....៧

➤ បរិយាយទូទៅនៃវិស័យមីក្រូហិរញ្ញវត្ថុ.....៩

➤ ព័ត៌មានប្រតិបត្តិការ.....១៣

➤ រចនាសម្ព័ន្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី.....១៧

➤ គណៈគ្រប់គ្រង.....១៩

➤ សកម្មភាពផ្សេងៗរបស់គ្រឹះស្ថាន ប្រចាំឆ្នាំ២០១៩.....២៦

- សកម្មភាពនៃការតាំងពិព័រណ៍ និងផ្សព្វផ្សាយផលិតផល.....២៧
- ការចូលរួមសម្អាតបរិស្ថានប្រចាំឆ្នាំ២០១៩.....២៩
- ការប្រកួតកីឡាប្រចាំឆ្នាំ២០១៩.....៣១
- កម្មវិធីចាប់រង្វាន់ និងផ្តល់រង្វាន់ដល់អតិថិជន និងដៃគូសហការណ៍របស់ អាក់ទីវភីភល ភីអិលស៊ី.....៣៣
- ពិធីសាយភោជនាហារជាមួយដៃគូសហការណ៍របស់ អាក់ទីវភីភល ភីអិលស៊ី.....៣៧
- ការលើកទឹកចិត្ត និង ឧបត្ថម្ភដល់កីឡាករទូកង.....៣៩

➤ សេវាកម្ម និង ផលិតផលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី.....៤១

➤ ទីស្នាក់ការ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី.....៤៥

➤ របាយការណ៍ហិរញ្ញវត្ថុ.....៥០

# ប្រវត្តិសង្ខេប




គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី ហៅកាត់ថា អេភី (Acitve People´s Micorfinance Institution PLC, Called APMFI) បានចុះបញ្ជីពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ ក្រុមហ៊ុននេះបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ក្រោមអាជ្ញាប័ណ្ណបញ្ជីលេខ ០០០០៩៤២៩ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១ និងទទួលអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ពីធនាគារជាតិនៃកម្ពុជា (ធនាគារកណ្តាលនៃប្រទេសកម្ពុជា) ដើម្បីធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ តទៅ។

អាក់ទីវភីភល ភីអិលស៊ី ត្រូវបានវិនិយោគដើមទុនទាំងស្រុងពីក្រុមហ៊ុនមេរបស់ប្រទេសជប៉ុនឈ្មោះ Business Partner Co.,Ltd.។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី បានបង្កើនដើមទុនរបស់ខ្លួនជាបន្តបន្ទាប់ ដើម្បីបំពេញតម្រូវការ របស់ប្រជាជនកម្ពុជាជាលក្ខណៈផ្តល់ហិរញ្ញវត្ថុខ្នាតតូច។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ អាក់ទីវភីភល ទទួលបានការអនុម័តពីធនាគារជាតិនៃកម្ពុជា លើសំណើសុំបង្កើនដើមទុនរបស់ខ្លួនពីចំនួន ១០,០០១,៨០០ ដុល្លារអាមេរិក រហូតដល់ ២០,០០០,០០០ ដុល្លារអាមេរិក តាមរយៈលិខិតអនុម័តលេខ ធ៧-០២០-១៦២ ឆត ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ របស់ធនាគារជាតិនៃកម្ពុជា ហើយអាក់ទីវភីភល ភីអិលស៊ី បានពង្រីកសាខារបស់ខ្លួនចំនួន ១៦សាខា៖

## ២០១១

- ទទួលអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ពីធនាគារជាតិនៃកម្ពុជា
- ចុះបញ្ជីនៅ ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនាមជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

## ២០១២

- បង្កើនដើមទុនពី ៣០០.០០០ដុល្លារ ដល់ ៧៩១.៨០០ដុល្លារ
- ផ្លាស់ប្តូរទីតាំងថ្មី ដែលមានអាសយដ្ឋាននៅផ្ទះលេខ ១៤៩សេ ផ្លូវលេខ១៤៣ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

## ២០១៣

- បង្កើនដើមទុនពី ៧៩១.៨០០ដុល្លារ ដល់ ៥.០០១.៨០០ដុល្លារ
- ផ្លាស់ប្តូរទីតាំងថ្មី ដែលមានអាសយដ្ឋាននៅអាគារលេខ៣៥-៣៧ ផ្លូវលេខ២១៤ សង្កាត់បឹងរាំង ខណ្ឌ៧មករា រាជធានីភ្នំពេញ
- បង្កើតសាខាខេត្តសៀមរាប និងសាខាខណ្ឌបឹងកេងកង៣

## ២០១៤

- បង្កើតសាខាខណ្ឌសែនសុខ

## ២០១៥

- បង្កើនដើមទុនពី៥.០០១.៨០០ ដុល្លារ ដល់ ៨.៥០១.៨០០ ដុល្លារ

## ២០១៦

- បង្កើនដើមទុនពី ៨.៥០១.៨០០ ដុល្លារ ដល់ ១០.០០១.៨០០ ដុល្លារ
- បង្កើតសាខាខេត្តបាត់ដំបង និងសាខាខេត្តកំពង់ចាម

## ២០១៧

- ផ្លាស់ប្តូរទីតាំងថ្មី ដែលមានអាសយដ្ឋាននៅ អាគារលេខ៨៨ ផ្លូវលេខ២១៤ ភូមិ៤ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ
- បង្កើតសាខា ខេត្តកណ្តាល សាខាខេត្តតាកែវ និងសាខាខណ្ឌទួលគោក

## ២០១៨

- បង្កើត សាខាខណ្ឌមានជ័យ ខណ្ឌច្បារអំពៅ ខណ្ឌជ្រោយចង្វា ខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ស្ពឺ

## ២០១៩

- បង្កើនដើមទុនពី ១០.០០១.៨០០ ដុល្លារ ដល់ ២០.០០០.០០០ ដុល្លារ
- បង្កើត សាខាត្បូងឃ្មុំ និងសាខាព្រែកព្នៅ



## ទស្សនៈវិស័យ

- យើងមានបំណងក្លាយទៅជាគ្រឹះស្ថានហិរញ្ញវត្ថុមួយឈានមុខគេ តាមរយៈការផ្តល់សេវាកម្មល្អប្រសើរ និងរីកចម្រើនប្រកបដោយស្ថេរភាព។

## បេសកកម្ម

- យើងធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅ របស់ប្រជាជនកម្ពុជា តាមរយៈការចូលរួម និងផ្តល់នូវឥណទានដោយប្រកាន់ខ្ជាប់ភាពជាដៃគូនៃអាជីវកម្មហិរញ្ញវត្ថុ។

## ពាក្យស្លោករបស់គ្រឹះស្ថាន

- យើងស្តាប់លោកអ្នក គិតជាមួយលោកអ្នកដើម្បីបង្កើត ដំណោះស្រាយដ៏ល្អបំផុតសម្រាប់ភាពជោគជ័យរបស់លោកអ្នក។

## គោលការណ៍ណែនាំ

- **អាក់ទីវភីភល ភីអិលស៊ី** នឹងផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋកម្ពុជាទូទៅដោយមិនប្រកាន់វណ្ណៈ។
- **អាក់ទីវភីភល ភីអិលស៊ី** នឹងផ្តល់សេវាហិរញ្ញវត្ថុដែលមានលក្ខណៈបត់បែន និងងាយស្រួលជាងគេ។
- **អាក់ទីវភីភល ភីអិលស៊ី** ប្តេជ្ញាគោរព និងអោយតម្លៃអតិថិជនរបស់ខ្លួនជាអាទិភាព។
- **អាក់ទីវភីភល ភីអិលស៊ី** ប្តេជ្ញាប្រកាន់ខ្ជាប់នូវអត្តចរិក និងស្តង់ដារការងារដើម្បី ធានាបាននូវភាពជឿជាក់។
- **អាក់ទីវភីភល ភីអិលស៊ី** ប្តេជ្ញាផ្តល់សេវាកម្ម និងទំនាក់ទំនងល្អបំផុតដល់ប្រជាពលរដ្ឋគ្រប់រូប។
- **អាក់ទីវភីភល ភីអិលស៊ី** ជាគ្រឹះស្ថានរៀនសូត្រដែលមានការផ្លាស់ប្តូរ និងការចែករំលែកនូវព័ត៌មានសមស្របដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍បុគ្គលិកការបណ្តុះបណ្តាល ព្រមទាំងរួមចំណែកក្នុងការកែលម្អគោលការណ៍ និងប្រព័ន្ធ។

## ក្រមអនុវត្តន៍របស់ អាក់ទីវភីភល ភីអិលស៊ី

- **ការជៀសវាងបំណុលលើសលប់** ៖ យើងនឹងផ្តល់ឥណទានតាមលទ្ធភាពសងរបស់អតិថិជន និងរកវិធីដើម្បីបញ្ជៀសបំណុលលើសលប់តាមការដែលអាចធ្វើបាន។
- **ក្រមសីលធម៌របស់បុគ្គលិក** ៖ យើងមានការអប់រំបន្ថែម និងប្រកាន់ខ្ជាប់នូវឥរិយាបថប្រកបដោយក្រមសីលធម៌ខ្ពស់ គោរពចំពោះអតិថិជនគ្រប់មជ្ឈដ្ឋានពីបុគ្គលិកគ្រប់លំដាប់ថ្នាក់។
- **សេរីភាពក្នុងការជ្រើសរើស** ៖ អតិថិជនមានសិទ្ធិជ្រើសរើសផលិតផល និងសេវារបស់យើងដែលសមស្របនឹងមុខរបរឬតម្រូវការ។
- **យន្តការឆ្លើយតបចំពោះមតិយោបល់** ៖ យើងនឹងទទួលយកនូវមតិយោបល់ និងឆ្លើយតបអោយបានសមរម្យបំផុត។





**លោក: TATSUHIRO Kurihara**

អគ្គនាយកប្រតិបត្តិ

# របាយការណ៍ប្រចាំឆ្នាំ ២០១៩ សារពីអគ្គនាយកប្រតិបត្តិ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី ទទួលបានអាជ្ញាប័ណ្ណអាជីវកម្មពីក្រសួងពាណិជ្ជកម្មក្នុងខែមីនា ឆ្នាំ ២០១១ និងអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុពី ធនាគារជាតិនៃកម្ពុជា នៅខែឧសភា ឆ្នាំ២០១១។ បន្ទាប់មកក្រុមហ៊ុន Business Partner Co., Ltd ដែលជាម្ចាស់ភាគហ៊ុននៅប្រទេសជប៉ុនបានទិញភាគហ៊ុនទាំងអស់ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី ចំនួន១០០% ហើយគ្រឹះស្ថានបានចាប់ផ្តើមអាជីវកម្ម ក្នុងនាមជាក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុជប៉ុន នៅខែធ្នូឆ្នាំ ២០១២។ នៅក្នុងគ្រានោះផងដែរ ចំនួនសមតុល្យសាច់ប្រាក់យើងមានត្រឹមតែ ១៨០,០០០ ដុល្លារ រីឯចំនួនបុគ្គលិកមានចំនួន ៦ នាក់ប៉ុណ្ណោះ។ មានន័យថាក្រុមហ៊ុនរបស់យើងមានលក្ខណៈតូចណាស់កាលពីដើមឡើយ។ ប៉ុន្តែក្នុងពេលនេះ គ្រឹះស្ថានមានចំនួនសមតុល្យមានចំនួន ៦២៩៩០.០០០ ដុល្លារអាមេរិក ហើយចំនួនបុគ្គលិកមានចំនួន ៥៩០ នាក់។ ក្រៅពីនេះមានសាខាមានចំនួន ១៦ បន្ថែម ហើយអតិថិជនមានចំនួន ៩១.២៣៧ នាក់។ យើងបានបន្តការរីកចម្រើនអស់រយៈពេល ៧ ឆ្នាំដោយសារតែការគាំទ្ររបស់អ្នក។ យើងនឹងមិនបោះបង់ចោលនូវការពង្រីកអាជីវកម្មរបស់យើងឡើយហើយបន្តខិតខំបន្ថែមទៀត។

តួនាទីសំខាន់បំផុតរបស់យើង គឺការផ្តល់អត្ថប្រយោជន៍ដល់អតិថិជន បុគ្គលិក និងសង្គមទាំងមូលនៅក្នុងប្រទេសកម្ពុជា។ យើងបានផ្តល់ជូនអតិថិជននូវសេវាកម្មតាមតម្រូវការ ហើយគាំទ្រដល់ជីវភាពរស់នៅប្រចាំថ្ងៃ និងអាជីវកម្មរបស់ពួកគេ។ យើងកំពុងធ្វើឱ្យពួកគាត់ទទួលបាននូវស្ថានភាពល្អ ដែលជាការគ្រប់គ្រងប្រកបដោយស្ថេរភាពរបស់ក្រុមហ៊ុនរបស់យើង ការបង្កើនឱកាសការងារ ការបង់ពន្ធមានលក្ខណៈស្ថេរភាព និងការផ្តល់សេវាកម្មប្រកបដោយស្ថេរភាពដល់អតិថិជនដោយសារតែសកម្មភាពរបស់យើង។

តួនាទីនឹងមិនត្រូវបានផ្លាស់ប្តូរ ទោះបីសង្គមនៅកម្ពុជាមានការកែលំអយ៉ាងឆាប់រហ័សក៏ដោយ។ យើងនឹងជូនដំណឹងពីចក្ខុវិស័យដែលយើងបានតំរែតម្រង់ចាប់តាំងពីក្រុមហ៊ុនរបស់យើងបានបង្កើតឡើងដល់បុគ្គលិកដែលមិនត្រឹមតែជាអ្នកគ្រប់គ្រងជាន់ខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែសមាជិកទាំងអស់ក៏ដូចជាបុគ្គលិកថ្មីដែរ។

ដើម្បីក្លាយទៅជា" គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលនៅជិតលោកអ្នកបំផុតនៅក្នុងប្រទេសកម្ពុជា" ដែលជាទីត្រូវការរបស់អតិថិជនជាច្រើន យើងនៅតែបន្តការខិតខំពង្រីក និងពង្រឹងតួនាទីរបស់យើងបន្ថែមទៀត ដោយផ្តោតលើការគោរពតាមក្រមសីលធម៌ ក្នុងការប្រកបអាជីវកម្ម និងការរៀបចំប្រព័ន្ធគ្រប់គ្រងឲ្យបានល្អ ដើម្បីសម្រេចឲ្យបាននូវការរីកចម្រើនខ្លាំងជាងនេះទៅទៀត។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី សូមអរគុណខ្លាំងណាស់សម្រាប់ការបន្តគាំទ្រនិងលើកទឹកចិត្ត។

**លោក**: **TATSUHIRO Kurihara**

**អគ្គនាយក**

# បរិយាយទូទៅនៃវិស័យហិរញ្ញវត្ថុ

ការរីកចម្រើនគ្រប់វិស័យនៃសេដ្ឋកិច្ច និងស្ថិរភាពនយោបាយ គឺជាកត្តាលីករបង្កើនជំនឿទុកចិត្តរបស់សាធារណជន និងវិនិយោគបរទេស ក៏ដូចជាការងពង្រឹងភាពរឹងមាំ និងសុខុមាលភាព មកលើប្រព័ន្ធធនាគារនៅកម្ពុជា។ វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបានបន្តរីកចម្រើនគួរអោយកត់សម្គាល់ និងប្រកបដោយនិរន្តរភាពទាំងវិសាលភាព ទំហំប្រតិបត្តិការ និងប្រាក់ចំណេញ គិតមកត្រឹមដំណាច់ឆ្នាំ២០១៩ ប្រព័ន្ធធនាគារនៅកម្ពុជា រួមមាន៖ ធនាគារពាណិជ្ជ ៤៧ (ធនាគារក្នុងស្រុក ១៧ ធនាគារបុត្តសម្ព័ន្ធ ១៧ និងធនាគារបរទេស ១៣) ធនាគារឯកទេស ១៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៧៦ គ្រឹះស្ថានឥណទានជនបទ ២៤៥ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១៥ អ្នកដំណើរការតតិយភាគី ៤ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ២១ ក្រុមហ៊ុនចែករំលែងព័ត៌មានឥណទាន ១ ការិយាល័យតំណាងធនាគារបរទេស ៦ និងអាជីវកម្មប្តូរប្រាក់ ២.៩១៣។

វិស័យមីក្រូហិរញ្ញវត្ថុនៅតែបន្តការរីកចម្រើនគួរឲ្យកត់សម្គាល់ និងប្រកបដោយនិរន្តរភាព។ កត្តានេះបានបង្ហាញពីការគាំទ្រនិងជំនឿទុកចិត្តរបស់សាធារណជន និងការទទួលយកសេវាហិរញ្ញវត្ថុផ្លូវការពីសំណាក់ប្រជាជននៅតាមជនបទ។ ទំហំទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើង ៣២,៨% ដល់ ៣៥,៩ ទ្រីលានរៀល (៨,៨% ប៊ីលានដុល្លារអាមេរិក) ដែលគាំទ្រដោយកំណើនមូលនិធិភាគទុក ២៧,៨% ដល់ ៦,៩% ទ្រីលានរៀល (១,៧ ប៊ីលានដុល្លារអាមេរិក)។

ជាមួយគ្នានេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅតែបន្តរក្សាបាននូវសក្តានុពលនៃការលូតលាស់និងនិរន្តភាពរបស់ខ្លួន ដោយឆ្លុះបញ្ចាំងតាមរយៈអនុបាត ROA ២,៨% ROE ១៤,៨% និងអនុបាតឥណទានមិនដំណើរការត្រឹមកម្រិត ០,៨%។ ការណ៍នេះ បានបង្ហាញពីភាពប្រសើរឡើងនៃការគ្រប់គ្រងគុណភាពទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ជាមួយគ្នានេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបន្តគោរពបានតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ននានារបស់ធនាគារជាតិ នៃកម្ពុជា ដោយការរក្សាបាននូវអនុបាតសាធនភាព ១៨,៩% និងអនុសន្ធនីយភាព ១៧៨,១%។

ទោះបីវិស័យនេះបានបន្តការរីកចម្រើនប្រកបដោយមោទនភាពយ៉ាងណាក្តី ប៉ុន្តែនៅប្រឈមនឹងបញ្ហាចម្បងៗមួយ

ចំនួនដូចជា៖

១. ការប្រកួតប្រជែងទីផ្សារកាន់តែខ្លាំងក្លាជាងមុនទាំង គ្រឹះស្ថានផ្លូវការ និងមិនផ្លូវការ

២.ការកសាងសមត្ថភាពធនធានមនុស្សអោយស្របតាមការរីកចម្រើនស្របតាមបច្ចេកវិទ្យាហិរញ្ញវត្ថុ

៣.ការអនុវត្តអោយបានពេញលេញតាម IFRS និង

៤.ការស្វែងរកប្រភពទុនដែលមានតម្លៃកាន់តែសមរម្យ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានបន្តពង្រឹងនិងពង្រីកវិសាលភាព និងទំហំប្រតិបត្តិការហិរញ្ញវត្ថុរបស់ខ្លួនក្នុងការផ្តល់សេវាកម្មជូនដល់ប្រជាជននៅតាមជនបទ។ ជាក់ស្តែងបណ្តាញប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានគ្របដណ្តប់ទូទាំង ២៥ ខេត្ត-ក្រុង ជាមួយ ១.៤៥៣ ការិយាល័យ នៅទូទាំងប្រទេស គណនីប្រាក់បញ្ញើអតិថិជនបានកើនដល់ ២.៧៨១.១៣០ គណនី និងគណនីឥណទានអតិថិជនបានកើនដល់ ២.១០៩.១៧០ គណនី។ ទន្ទឹមនេះ ដោយមានការយកចិត្តទុកដាក់ពីធនាគារជាតិ នៃកម្ពុជាក្នុងការបន្តលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុផ្លូវការ ប្រជាជននៅតាមជនបទកាន់តែច្រើនបានងាកមកប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុផ្លូវការ ជំនួសឲ្យការប្រើប្រាស់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ។ គោលការណ៍នេះបានបង្កលទ្ធភាពដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការរួមចំណែកយ៉ាងសំខាន់ ក្នុងការលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា តាមរយៈការផ្តល់ទុនដល់ប្រជាជនដែលប្រកបអាជីវកម្មខ្នាតតូចនិងមធ្យម។

ចំពោះគ្រឹះស្ថានឥណទានជនបទមានចំនួន ២៤៥ ដោយមានទំហំទ្រព្យសកម្មសរុប ៤៣៧,៤ ប៊ីលានរៀល (១០៧,៣ លានដុល្លារអាមេរិក) និងសំពៀតឥណទានសរុប ៣៥៣,៧ ប៊ីលានរៀល (៨៦,៨ លានដុល្លារអាមេរិក) ដែលបានផ្តល់ដល់អតិថិជនសរុបដែលមាន ១៧០,០១៤ គណនី។ សំពៀតឥណទានត្រូវបានបែងចែងកវិស័យនានា ដូចជាកសិកម្ម ៣៥,៨% ពាណិជ្ជកម្ម ២១,៣% ក្រុមគ្រួសារ១៦,៣% សេវាកម្ម ១៣,៥% ដឹកជញ្ជូន ០,៤% សំណង់ ៥,៩% និងផ្សេងៗ ៦,៨%។ អនុបាតឥណទានមិនដំណើរការរបស់គ្រឹះស្ថានឥណទានជនបទមានកម្រិតខ្ពស់ដល់ ១០,៦% ដោយសារមិនមានវត្ថុបញ្ចាំ និងកង្វះខាតក្នុងការគ្រប់គ្រងឥណទានរបស់គ្រឹះស្ថាន។ ធនាគារជាតិ នៃកម្ពុជា បានបន្ត

ពង្រឹងក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ ព្រមទាំងការត្រួតពិនិត្យលើឯកសារនិងការត្រួតពិនិត្យដល់ទីកន្លែង ដើម្បីធានាការប្រតិបត្តិតាម និងការអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈក្នុងការផ្តល់សេវាហិរញ្ញវត្ថុជូនអតិថិជន។ ក្នុងឆ្នាំ២០១៩ ធនាគារជាតិ នៃកម្ពុជា បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពី វិស័យមីក្រូហិរញ្ញវត្ថុ ថ្នាក់ខេត្ត ១លើក និងថ្នាក់ស្រុកចំនួន ៦លើក ដែលមានអ្នកចូលរួមសរុបប្រមាណ ៣.៨៨៥ នាក់។ គោលបំណងសំខាន់ៗនៃសិក្ខាសាលានេះរួមមានៈ

I. ផ្សព្វផ្សាយអំពីប្រវត្តិនៃការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

II. ផ្សព្វផ្សាយក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា

III. លើកកម្ពស់ការយល់ដឹងពីសេវាកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណស្របច្បាប់

IV. ពិភាក្សាពីបញ្ហាប្រឈមនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

V. ស្វែងរកដំណោះស្រាយនិងឆ្លើយតបនូវសំណូមពររបស់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានចំពោះការប្រើប្រាស់សេវាកម្មមីក្រូហិរញ្ញវត្ថុ។

* អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានបន្តរក្សាការប្រាក់ឥណទានរបស់ខ្លួនទាបជាងកម្រិតកំណត់របស់ធនាគារនៃកម្ពុជា។ អត្រាការប្រាក់លើឥណទានថ្លឹងជាមធ្យមជារៀលមានកម្រិត ១៧,៩% និងដុល្លារអាមេរិកមាន ១៦,០% ខណៈដែលអត្រាការប្រាក់បញ្ញើថ្លឹងជាមធ្យម ទាំងជារៀលនិងដុល្លារអាមេរិក មានកម្រិតប្រហាក់ប្រហែលគ្នានឹងឆ្នាំមុន ក្នុងអត្រា ៧,៩% និង ៧,៧% រៀងគ្នា។ លើសពីនេះ ការដាក់ពិដានអត្រាការប្រាក់ឥណទាន ដែលតម្រូវអោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់ឥណទានក្នុងអត្រាការប្រាក់មិនលើសពី ១៨% (មានប្រសិទ្ធភាពចាប់ពីខែ មេសា ឆ្នាំ ២០១៧ ) ។ ទន្ទឹមនេះការកើនឡើងនៃការប្រកួតប្រជែងនៅក្នុងទីផ្សារ បានជម្រុញឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបង្កើនការយកចិត្តទុកដាក់ក្នុងការពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ និងការកាត់បន្ថយចំណាយប្រតិបត្តិការ ដែលជួយបន្ថយអត្រាការប្រាក់លើឥណទានទាំងជារៀល និងដុល្លារអាមេរិក។

ជាងកម្រិតកំណត់របស់ធនាគារនៃកម្ពុជា។ អត្រាការប្រាក់លើឥណទានថ្មីៗជាមធ្យមជារៀលមានកម្រិត ១៧,៩% និងដុល្លារអាមេរិកមាន ១៦,០% ខណៈដែលអត្រាការប្រាក់បញ្ញើថ្មីៗជាមធ្យម ទាំងជារៀលនិងដុល្លារអាមេរិក មានកម្រិតប្រហាក់ប្រហែលគ្នានឹងឆ្នាំមុន ក្នុងអត្រា ៧,៩% និង ៧,៧% រៀងគ្នា។ ទន្ទឹមនេះ ការកើនឡើងនៃការប្រកួតប្រជែងនៅ៦លើកក្នុងទីផ្សារ បានជម្រុញឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបង្កើនការយកចិត្តទុកដាក់ក្នុងការពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ និងការកាត់បន្ថយចំណាយប្រតិបត្តិការ ដែលជួយបន្ថយអត្រាការប្រាក់លើឥណទានទាំងជារៀលនិងដុល្លារអាមេរិក។





# ព័ត៌មានប្រតិបត្តិការ

## ព័ត៌មានប្រតិបត្តិការ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|---|
| ផលប័ត្រឥណទានសរុប (ដុល្លារ) | ១៨,១៣២,៧៥៤ | ២១,៧២១,០៦៤ | ២៨,៧២៧,៩៦២ | ៤០,៣៨៨,១៧១ | ៦៥,៨៤១,៤៤២ |
| ចំនួនសាខា | ៤ | ៤ | ៩ | ១៤ | ១៦ |
| ចំនួនអតិថិជន | ១៩,១២៥ | ១៩,១៨១ | ៣៣,០០១ | ៥២,៤៣១ | ៧៩,៤៦៥ |

**ផលប័ត្រឥណទានសរុប** (គិតជាលានដុល្លារ)



## សាខា



២០១៩
១៦
២០១៨
១៤
២០១៧
៩
២០១៦
៤
២០១៥
៤


## អតិថិជន



២០១៩
៧៩,៤៦៥
២០១៨
៥២,៤៣១
២០១៧
៣៣,០០១
២០១៦
១៩,១៨១
២០១៥
១៩,១២៥

## សមតុល្យឥណទានតាមផលិតផល

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| ប្រភេទផលិតផល | ២០១៨ | ២០១៩ |
|---|---|---|
| បង់រំលស់គ្រឿងចក្រកសិកម្ម | ២,៥៧០,៣៥៤ | ១,១៩០,៦៤៥ |
| បង់រំលស់រថយន្ត | ១,៦៨៤,៩០៥ | ៥,២០៧,៨៥៥ |
| បង់រំលស់គ្រឿងអេឡិចត្រូនិច | ៣,៣៤៩,៣៩២ | ៦,២៩៨,០៥១ |
| បង់រំលស់ដី | ៧៤០,៩១៣ | ៨៧១,៦៥៧ |
| បង់រំលស់ម៉ូតូ | ៩,៤៤១,៨៨៧ | ២៤,៣៣៨,៤៥៥ |
| ឥណទានរហ័ស | ៤,៨៣៣,៣៨០ | ២,០៧៦,៣៩៨ |
| ឥណទានប្រើប្រាស់ទូទៅ | ១៧,៧៦៧,៣៤២ | ២៥,៨៥៨,៣៨១ |
| សរុប | ៤០,៣៨៨,១៧១ | ៦៥,៨៤១,៤៤២ |




ビジネスパートナーグループ
第二十期 全体会議・表彰式

# រចនាសម្ព័ន្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ប្រចាំឆ្នាំ២០១៩






**នាយកដ្ឋានរដ្ឋបាល**

# គណៈគ្រប់គ្រង



## លោក សុន គឹមសា

នាយកចាត់ការទូទៅ

លោក សុន គឹមសា ចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី ចាប់ពី ខែតុលា ឆ្នាំ២០១៤ ដែលមានតួនាទីជាបុគ្គលិកទូទៅ។ មុនពេល លោក សុន គឹមសា ចូលបំរើការងារជាមួយ អាក់ទីវភីភល ភីអិលស៊ី លោកធ្លាប់មានបទពិសោធន៍ ធ្វើការនៅក្រុមហ៊ុន Business Partner Co.Ltd នៃ ប្រទេសជប៉ុនអស់រយៈពេលមួយឆ្នាំ ហើយលោកបាន ឆ្លងកាត់ការធ្វើបានរៀបចំឡើងដោយក្រុមហ៊ុនផងដែរ។

លោក សុន គឹមសា បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែក ហិរញ្ញវត្ថុ និងធនាគារ នៅសាកលវិទ្យាល័យណាហ្គូយ៉ានៃ ប្រទេសជប៉ុនកាលពីឆ្នាំ២០១០។ ជាមួយគ្នាបទពិសោធន៍ ច្រើនជាង ៥ឆ្នាំ ក្នុងការបម្រើការងារជាមួយគ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី ពេលនេះ លោក សុន គឹមសា កាន់តួនាទីជានាយកចាត់ការទូទៅ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី។



**លោក ឯក ស៊ីនដេង**

នាយកព័ត៌មានវិទ្យា

លោក ឯក ស៊ីនដេង ចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី ចាប់ពីខែមិថុនា ឆ្នាំ២០១៥ ក្នុងតួនាទីជាប្រធានផ្នែកព័ត៌មានវិទ្យា។ មុនពេលលោក ឯក ស៊ីនដេង ចូលបំរើការងារជាមួយ អាក់ទីវភីភល ភីអិលស៊ី លោកធ្លាប់មានបទពិសោធន៍ជាងប្រាំឆ្នាំ ក្នុងតួនាទីជាមន្ត្រីជាន់ខ្ពស់ផ្នែកព័ត៌មានវិទ្យា និង មានបទពិសោធន៍ជាច្រើនទាក់ទងនឹងការបង្កើតគេហទំព័រ និងបង្កើតប្រព័ន្ធប្រើប្រាស់ផ្សេងៗទៀត។

លោកបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជំនាញវិទ្យាសាស្ត្រកុំព្យូទ័រ និងវិស្វករ ក្នុងឆ្នាំ២០០៩ និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្មក្នុងឆ្នាំ២០១២ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។



## លោកស្រី ជា ធិតា

នាយិការរៀបចំផែនការសារជីវកម្ម

លោកស្រី ជា ធិតា ចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី នៅឆ្នាំ២០១៥ ក្នុងតួនាទីជាប្រធានគណនេយ្យ។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៧ លោកស្រី ជា ធិតា បានបំពេញតួនាទីជាប្រធានផ្នែករៀបចំផែនការសារជីវកម្មរបស់គ្រឹះស្ថាន។ មុនពេលចូលបម្រើការងារជាមួយ អាក់ទីវភីភល ភីអិលស៊ី លោកស្រី ជា ធិតា ធ្លាប់មានបទពិសោធន៍ជាមួយ គ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនដទៃទៀតរយៈពេលសរុបជាង១០ឆ្នាំ ដែលមានតួនាទីជាប្រធានផ្នែកគណនេយ្យ ប្រធានផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល។

លោកស្រី ជា ធិតា បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជំនាញគណនេយ្យ និងហិរញ្ញវត្ថុ នៅសាកលវិទ្យាបៀលប្រាយ ឆ្នាំ២០០៩។ បច្ចុប្បន្នលោកស្រី បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ជំនាញហិរញ្ញវត្ថុ និងធនាគារ។

លោកស្រីក៏បានឆ្លងកាត់វគ្គសិក្សាជំនាញផ្សេងៗដូចជាគណនេយ្យកុំព្យូទ័រ Quick Books, Access, Excel ជាដើម។



**លោក វង្ស ប៊ុនឈឿន**

នាយកសវនកម្មផ្ទៃក្នុង

លោក វង្ស ប៊ុនឈឿន ជាជនជាតិខ្មែរ។ លោកបានទទួលសញ្ញាបត្របរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ពីសាកលវិទ្យាល័យមេគង្គកម្ពុជា និងកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកធនាគារ និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យវេសស្ទើន។ លោកបានចូលរួមវគ្គសិក្សាជាច្រើនដូចជា៖ ជំនាញវាយតម្លៃហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង សវនកម្មសម្រាប់ការលួចបន្លំផ្ទៃក្នុង ការរៀបចំផែនការ និងគ្រប់គ្រងពេលវេលា ការគ្រប់គ្រងហានិភ័យស្ថាប័នមីក្រូហិរញ្ញវត្ថុ និងមូលដ្ឋានពន្ធ។ លោកក៏បានចូលរួមវគ្គសិក្សាផ្សេងទៀតដូចជា៖ ភាពជាអ្នកដឹកនាំ និងភាពជោគជ័យនិងការវិភាគហិរញ្ញវត្ថុសាជីវកម្មជាន់ខ្ពស់។ លោកធ្លាប់បានបម្រើការងារអស់រយៈពេលជាង ៣ឆ្នាំ នៅសាកលវិទ្យាល័យមេគង្គកម្ពុជា ផ្នែករដ្ឋបាល។ លោកក៏ធ្លាប់បានបម្រើការងារអស់រយៈពេលជាង១០ឆ្នាំ នៅមីក្រូហិរញ្ញវត្ថុ ធនាគារឯកទេស ជាមន្ត្រីសវនកម្មផ្ទៃក្នុង ប្រធានសវនកម្មផ្ទៃក្នុង និងជានាយកសវនកម្មផ្ទៃក្នុង។

លោកបានចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ក្នុងឆ្នាំ ២០១៩ មានតួនាទីជា នាយកសវនកម្មផ្ទៃក្នុង មកដល់បច្ចុប្បន្ននេះ។



**លោកស្រី លឹម លីដា**

នាយិកាកិច្ចការទូទៅ និងធនធានមនុស្ស

លោកស្រី លឹម លីដា ចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី ចាប់ពីខែកញ្ញា ឆ្នាំ២០១៣ ក្នុងមុខតំណែងផ្សេងៗជាច្រើន ដូចជា មន្ត្រីផ្នែកលក់ ប្រធានក្រុមគ្រូបណ្តុះបណ្តាល មន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនងអតិថិជន និងនាយិកាគ្រូបណ្តុះបណ្តាល។
ចាប់ពីខែមករាឆ្នាំ២០១៩ មកដល់បច្ចុប្បន្នមានតួនាទីជា នាយិកាកិច្ចការទូទៅ និងធនធានមនុស្ស។

មុនពេល លោកស្រី លឹម លីដា ចូលបម្រើការងារជាមួយអាក់ទីវភីភល ភីអិលស៊ី លោកស្រីធ្លាប់មានបទពិសោធន៍ជាងប្រាំឆ្នាំក្នុងតួនាទីជាមន្ត្រីទំនាក់ទំនងអតិថិជនតាមទូរស័ព្ទ ។

លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជំនាញធនាគារ និងហរិញ្ញវត្ថុ ក្នុងឆ្នាំ២០១២ ។ លោកស្រីក៏បានឆ្លងកាត់វគ្គសិក្សាជំនាញផ្សេងៗដូចជា ច្បាប់ស្តីពីការងារ , ភាពជាអ្នកដឹកនាំ , វគ្គបណ្តុះបណ្តាលគ្រូហ្វឹកហ្វឺន , Word, Excel និង Advanced ជាដើម។




លោក Yusuke Koizumi បានចូលបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨ ក្នុងតួនាទីជាប្រធានផ្នែកហិរញ្ញវត្ថុ។ មុនពេលចូលបម្រើការងារជាមួយ អាក់ទីវភីភល ភីអិលស៊ី

លោក Yusuke Koizumi ធ្លាប់បម្រើការងារជាប្រធានផ្នែកគ្រប់គ្រងហិរញ្ញវត្ថុនៅក្រុមហ៊ុន Hikari Tsushin.Inc រយៈពេលជាង៣ឆ្នាំ និងជាប្រធានផ្នែកគ្រប់គ្រងផែនការអាជីវកម្ម នៅក្រុមហ៊ុន Business Partner Co.,Ltd រយៈពេលជិត៧ឆ្នាំ។

លោក Yusuke Koizumi បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ជំនាញគ្រប់គ្រងអាជីវកម្ម នៅសាកលវិទ្យាល័យ Business Break Through University នៃប្រទេសជប៉ុន កាលពីឆ្នាំ២០១៨ កន្លងទៅ។ លើសពីនេះ លោកធ្លាប់បានឆ្លងកាត់វគ្គសិក្សាជំនាញផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងអាជីវកម្ម និងហិរញ្ញវត្ថុផងដែរ។

# សកម្មភាពផ្សេងៗរបស់គ្រឹះស្ថានប្រចាំឆ្នាំ២០១៩



## ១. សកម្មភាពនៃការតាំងពិព័រណ៍ និងការផ្សព្វផ្សាយផ្សេងៗរបស់ អាក់ទីវភីគល ភីអិលស៊ី

នៅក្នុងឆ្នាំ២០១៩ នេះ គ្រឹះស្ថានបានរៀបចំការតាំងពិព័រណ៍ និង ការផ្សព្វផ្សាយនូវផលិតផលឥណទានរបស់គ្រឹះស្ថាន ហើយទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់អតិថិជន និងសាធារណជន។




017 482 550
015 532 900
WAOJE

## ២. ការចូលរួមសម្អាតបរិស្ថានប្រចាំឆ្នាំ២០១៩

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី បានបង្កើតនូវកម្មវិធីចូលរួមសម្អាតទីក្រុង ក្នុងគោលបំណងដើម្បីរួមចំណែកថែរក្សាអនាម័យបរិស្ថានទីក្រុងស្អាត ដែលជាការឆ្លើយតបទៅតាមគោលនយោបាយស្តីពី "ទីក្រុងស្អាត សេវាល្អ" របស់រាជរដ្ឋាភិបាល ។




គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល
Active People's Microfinance Institution Plc
"យុទ្ធនាការសម្អាតទីក្រុង
ខ្ញុំចូលរួម អ្នកចូលរួម យើងចូលរួមទាំងអស់គ្នាដើម្បីបរិស្ថានស្អាត

## ៣. ការប្រកួតកីឡារបស់បុគ្គលិកប្រចាំឆ្នាំ២០១៩

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី បានបង្កើតកម្មវិធីប្រកួតកីឡាប្រចាំឆ្នាំ ដើម្បីឱ្យបុគ្គលិកទាំងអស់បានចែករំលែកបទពិសោធន៍ និងបង្ហាញនូវអត្ថន័យនៃការធ្វើការងារជាក្រុម ដើម្បីទទួលបានជោគជ័យ។




POCARI SWEAT
SPORT EVENT
Active People's Microfinance Institution Plc.

## ៤. កម្មវិធីចាប់ និងផ្តល់រង្វាន់ដល់អតិថិជន និងដៃគូសហការណ៍របស់អាក់ទីវភីភល ភីអិលស៊ី

គ្រឹះស្ថានបានធ្វើការចាប់រង្វាន់ និងប្រគល់រង្វាន់ដល់អតិថិជនដែលបានប្រើប្រាស់សេវាកម្ម និងដៃគូររបស់គ្រឹះស្ថាន។




គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី
Oppo F11 Pro
Oppo F11 Pro
LED
Clear Resolution Enhancer
X-Protection PRO
40
101.6 cm
R35 E


Lucky Draw
Active People's Microfinance Institution Plc


Lucky Draw
រង្វាន់ទី២
ដំណើរកំសាន្តទៅកាន់:
កោះភូកេត
រង្វាន់ទី៣
ដំណើរកំសាន្តទៅកាន់:
សាំងហ្គាពួរ
និងម៉ាឡេស៊ី
រង្វាន់ទី១
ដំណើរកំសាន្តទៅកាន់:
ហុង កុង

## ៥. ពិធីសាយភោជនាហារជាមួយដៃគូសហការរបស់ អាក់ទីវភីភល ភីអិលស៊ី

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី បានបង្កើតនូវកម្មវិធីសាយភោជនាហារ ជាមួយដៃគូសហការទាំងអស់របស់គ្រឹះស្ថាន ក្នុងគោលបំណងថ្លែងអំណរគុណ និងបន្តកិច្ចសហប្រតិបត្តិការដើម្បីឈានទៅរកភាពរីកចម្រើនពេលអនាគត។




គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី

## ៦. ការលើកទឹកចិត្ត និង ឧបត្ថម្ភដល់កីឡាករទូកង

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី បានឧបត្ថម្ភដល់កីឡាករទូកង ដើម្បីបង្ហាញពីការអបអរសាទរ និង គាំទ្រដល់ពិធីបុណ្យអុំទូក អកអំបុកសំពះព្រះខែនៃព្រះរាជាណាចក្រកម្ពុជា។




FREE
NVC

# សេវាកម្ម និង ផលិតផល របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី

**សេវាកម្ម៖**

អត្រាការប្រាក់ទាបសមរម្យ

* លក្ខខណ្ឌមានភាពងាយស្រួល
* សេវារហ័សទាន់ចិត្ត
* រកដំណោះស្រាយល្អបំផុតសម្រាប់លោកអ្នក និង
* ធ្វើអោយអស់លទ្ធភាពដើម្បីអោយសុបិន្តលោកអ្នកក្លាយជាការពិត។

## ផលិតផល

### ១. កម្ចីរហ័ស

សម្រាប់ផ្តល់ជូនដល់អតិថិជនដែលមានតម្រូវការបន្ទាន់។

| ប្រភេទកម្ចី | រូបិយប័ណ្ណ | ទំហំកម្ចី | រយៈពេលកម្ចី |
|---|---|---|---|
| កម្ចីរហ័ស | រៀល | ៤០០,០០០ - ២០,០០០,០០០ | ១២ - ៣៦ខែ |
| | ដុល្លារ | ១០០ - ៥,០០០ | |

### ២. កម្ចីបង់រំលស់ម៉ូតូ

សម្រាប់ផ្តល់ជូនដល់អតិថិជនដែលមានបំណងទិញម៉ូតូ ទៅប្រើប្រាស់តាមតម្រូវការប្រចាំថ្ងៃ។

| ប្រភេទកម្ចី | រូបិយប័ណ្ណ | ទំហំកម្ចី | រយៈពេលកម្ចី |
|---|---|---|---|
| កម្ចីបង់រំលស់ម៉ូតូ | រៀល | ៤០០,០០០ - ២០,០០០,០០០ | ១២ - ៦០ខែ |
| | ដុល្លារ | ១០០ - ៥,០០០ | |

## ៣. កម្ចីបង់រំលស់គ្រឿងអេឡិចត្រូនិច

សម្រាប់ផ្តល់ជូនដល់អតិថិជនដែលមានបំណងប្រើប្រាស់គ្រឿងអេឡិចត្រូនិច មានដូចជាទូរស័ព្ទ ទូរទស្សន៍ កុំព្យូទ័រ ។ល។

| ប្រភេទកម្ចី | រូបិយប័ណ្ណ | ទំហំកម្ចី | រយៈពេលកម្ចី |
|---|---|---|---|
| កម្ចីបង់រំលស់គ្រឿងអេឡិចត្រូនិច | រៀល | ៤០០,០០០ - ៨០,០០០,០០០ | ១២ - ៦០ខែ |
| | ដុល្លារ | ១០០ - ២០,០០០ | |

## ៤. កម្ចីឥណទានប្រើប្រាស់ទូទៅ

សម្រាប់ផ្តល់ជូនដល់អតិថិជនដែលខ្វះដើមទុនដើម្បីបង្កើតមុខរបរថ្មី ឬពង្រីកមុខរបរមានស្រាប់។

| ប្រភេទកម្ចី | រូបិយប័ណ្ណ | ទំហំកម្ចី | រយៈពេលកម្ចី |
|---|---|---|---|
| កម្ចីឥណទានប្រើប្រាស់ទូទៅ | រៀល | ៨០០៤,០០០ - ១២០,០០០,០០០ | ១២ - ៦០ខែ |
| | ដុល្លារ | ២០០១ - ៣០,០០០ | |

## ៥. កម្ចីឥណទានបង់រំលស់រថយន្ត

សម្រាប់ផ្តល់ជូនដល់អតិថិជនដែលមានបំណងទិញឡាន ទៅប្រើប្រាស់តាមតម្រូវការប្រចាំថ្ងៃ។

| ប្រភេទកម្ចី | រូបិយប័ណ្ណ | ទំហំកម្ចី | រយៈពេលកម្ចី |
|---|---|---|---|
| កម្ចីឥណទានបង់រំលស់រថយន្ត | រៀល | ២០,០០០,០០០ - ២០០,០០០,០០០ | ២៤ - ៨៤ខែ |
| | ដុល្លារ | ៥,០០០ - ៥០,០០០ | |

## ៦. កម្ចីឥណទានបង់រំលស់ដី

សម្រាប់ផ្តល់ជូនដល់អតិថិជនដែលមានបំណងចង់ទិញដីឡូហ៍បង់រំលស់។

| ប្រភេទកម្ចី | រូបិយប័ណ្ណ | ទំហំកម្ចី | រយៈពេលកម្ចី |
|---|---|---|---|
| កម្ចីឥណទានបង់រំលស់ដី | រៀល | ៤,000,000 - ១២0,000,000 | ១២ - ៦0ខែ |
| | ដុល្លារ | ១,000 - ៣0,000 | |

## ៧. កម្ចីឥណទានបង់រំលស់គ្រឿងចក្រកសិកម្ម

សម្រាប់ផ្តល់ជូនដល់អតិថិជនដែលមានតម្រូវការប្រើប្រាស់គ្រឿងចក្រកសិកម្ម ជាពិសេសផ្តល់ការសម្របសម្រួលដល់អតិថិជនដែលធ្វើកសិកម្ម។

| ប្រភេទកម្ចី | រូបិយប័ណ្ណ | ទំហំកម្ចី | រយៈពេលកម្ចី |
|---|---|---|---|
| កម្ចីឥណទានបង់រំលស់គ្រឿងចក្រកសិកម្ម | រៀល | ៤00,000 - ២៤0,000,000 | ១២ - ៦0ខែ |
| | ដុល្លារ | ១00 - ៦0,000 | |

## ៧. កម្ចីឥណទាន A-PLUS

សម្រាប់ផ្តល់ជូនដល់អតិថិជនដែលប្រើប្រាស់ ឬ កំពុងស្នើសុំកម្ចីបង់រំលស់គ្រឿងចក្រកសិកម្មតែប៉ុណ្ណោះ តាមរយៈការផ្តល់ជាសាច់ប្រាក់។

| ប្រភេទកម្ចី | រូបិយប័ណ្ណ | ទំហំកម្ចី | រយៈពេលកម្ចី |
|---|---|---|---|
| កម្ចី A-PLUS | រៀល | ៤00,000 - ៤,000,000 | ១២ - ៣៦ខែ |
| | ដុល្លារ | ១00 - ១,000 | |

# ទីស្នាក់ការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី



# ទីស្នាក់ការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី

## ទីស្នាក់ការកណ្តាល

អគារលេខ ៨៨, ផ្លូវលេខ ២១៤ កែង ១១៣, សង្កាត់បឹងព្រលិត, ខណ្ឌ៧មករា, រាជធានីភ្នំពេញ ,ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ៖
(៨៥៥) ២៣ ២១៤ ២៥៥
(៨៥៥) ៧៨ ៧៧៧ ៣៤០
សារអេឡិចត្រូនិច៖ info@apmfi.com.kh,
គេហទំព័រ៖ www.apmfi.com.kh ,
Facebook page៖ ActivePeopleMFI , App store៖ AP Mobile

## សាខាទួលទំពូង

ផ្ទះលេខ ១៤៩c, ផ្លូវលេខ១៤៣, សង្កាត់បឹងកេងកង៣, ខណ្ឌចំការមន, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ៖
(៨៥៥) ២៣ ២២៤ ១៦៥
(៨៥៥) ៧៨ ៧៧៧ ២៥៩

## សាខាសែនសុខ

ផ្ទះលេខ ៨៧-៨៩, ផ្លូវលេខ ១០១៩, សង្កាត់ទឹកថ្លា, ខណ្ឌសែនសុខ, រាជធានីភ្នំពេញ (ទល់មុខស្ថានីយ៍ទូរទស្សន៍អាស៊ីអាគ្នេយ៍) ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ៖
(៨៥៥) ២៣ ៨៨៣ ២៧០
(៨៥៥) ១៧ ៤៩៨ ៤០៥

## សាខាទួលគោក

ផ្ទះលេខ ៣A, ផ្លូវលេខ៣៥៥, ភូមិ១, សង្កាត់បឹងកក់ទី១, ខណ្ឌទួលគោក, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ៖
(៨៥៥) ២៣ ២៣១ ៩១២
(៨៥៥)៨១ ៩៩៤ ៨៣១

## សាខាខេត្តកំពង់ចាម

លេខ ៦៤, មហាវិថី ព្រះមុនីវង្ស(២២២) សង្កាត់ កំពង់ចាម, ក្រុងកំពង់ចាម, ខេត្តកំពង់ចាម, ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ៖
(៨៥៥) ៤២ ២១០ ៨៨៧
(៨៥៥) ៧១ ៣២៣៩ ៧៧៧

## សាខាខេត្តតាកែវ

ផ្ទះលេខ២ ផ្លូវលេខ២, ភូមិឡូរី, សង្កាត់រកាក្នុង, ក្រុងដូនកែវ, ខេត្តតាកែវ ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ៖
(៨៥៥) ៣២ ២១០ ៨៦០
(៨៥៥) ៣២២ ២១០ ៨៦១

## សាខាខេត្តបាត់ដំបង

ផ្ទះលេខ ២៣-២៥, ផ្លូវលេខ៣, សង្កាត់ស្វាយប៉ោ, ក្រុងបាត់ដំបង, ខេត្តបាត់ដំបង, ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ៖
(៨៥៥) ៥៣ ៧៣២ ៦០០
(៨៥៥) ៧១ ៣៣១៦ ៧៧៧

## សាខាខេត្តសៀមរាប

ផ្ទះលេខ ៨៨, ផ្លូវស៊ីវុត្ថា, ភូមិមណ្ឌល១, សង្កាត់ស្វាយដង្គំ, ក្រុងសៀមរាប, ខេត្តសៀមរាប ,ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ៖
(៨៥៥) ៦៣ ៧៦៦ ០០៧
(៨៥៥) ៧៨ ៧៧៧ ២៥២

## សាខាតាខ្មៅ

ផ្ទះលេខ ១៣៧D, ផ្លូវជាតិលេខ២, ភូមិតាខ្មៅ, សង្កាត់តាខ្មៅ ក្រុងតាខ្មៅ, ខេត្តកណ្ដាល, ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ ៖
(៨៥៥) ២៣ ៤២៥ ៦៧៨
(៨៥៥) ១៧ ២៧ ៦០ ៣១

## សាខាខេត្តកំពង់ចាម

លេខ ៦៤, មហាវិថី ព្រះមុនីវង្ស(២២២) សង្កាត់ កំពង់ចាម, ក្រុងកំពង់ចាម, ខេត្តកំពង់ចាម, ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ៖
(៨៥៥) ៤២ ២១០ ៨៨៧
(៨៥៥) ៧១ ៣២៣៩ ៧៧៧

## សាខាខេត្តតាកែវ

ផ្ទះលេខ២ ផ្លូវលេខ២, ភូមិឡូរី, សង្កាត់រកាក្នុង, ក្រុងដូនកែវ, ខេត្តតាកែវ ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ៖
(៨៥៥) ៣២ ២១០ ៨៦០
(៨៥៥) ៣២២ ២១០ ៨៦១

## សាខាខេត្តបាត់ដំបង

ផ្ទះលេខ ២៣-២៥, ផ្លូវលេខ៣, សង្កាត់ស្វាយប៉ោ, ក្រុងបាត់ដំបង, ខេត្តបាត់ដំបង, ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ៖
(៨៥៥) ៥៣ ៧៣២ ៦០០
(៨៥៥) ៧១ ៣៣១៦ ៧៧៧

## សាខាខេត្តសៀមរាប

ផ្ទះលេខ ៨៨, ផ្លូវស៊ីវុត្ថា, ភូមិមណ្ឌល១, សង្កាត់ស្វាយដង្គំ, ក្រុងសៀមរាប, ខេត្តសៀមរាប ,ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ៖
(៨៥៥) ៦៣ ៧៦៦ ០០៧
(៨៥៥) ៧៨ ៧៧៧ ២៥២

## សាខាតាខ្មៅ

ផ្ទះលេខ ១៣៧D, ផ្លូវជាតិលេខ២, ភូមិតាខ្មៅ, សង្កាត់តាខ្មៅ ក្រុងតាខ្មៅ, ខេត្តកណ្តាល, ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ ៖
(៨៥៥) ២៣ ៤២៥ ៦៧៨
(៨៥៥) ១៧ ២៧ ៦០ ៣១

## សាខាបន្ទាយមានជ័យ

សង្កាត់ពន្លា, ក្រុងសិរីសោភ័ណ្ឌ, ខេត្តបន្ទាយមានជ័យ, ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ ៖
(៨៥៥) ៦៤ ៧១០ ៥១៣
(៨៥៥) ៥៤ ៧១០ ៥១៨

## សាខាព្រែកព្នៅ

ផ្លូវជាតិលេខ៥ ភូមិកណ្តាល, សង្កាត់ព្រែកព្នៅ, ខណ្ឌព្រែកព្នៅ, រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ៖
(៨៥៥) ២៦ ៧៧ ៥១ ៥២

## សាខាត្បូងឃ្មុំ

ភូមិជើងឡង, សង្កាត់សួង, ក្រុងសួង, ខេត្តត្បូងឃ្មុំ ,ប្រទេសកម្ពុជា
ទំនាក់ទំនងទូរស័ព្ទលេខ៖
(៨៥៥) ៤៥ ២១ ១១ ៣១

### តំបន់ប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី



លេខចុះបញ្ជីពាណិជ្ជកម្មៈ
Co. ០០០០៩៤២៩

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេក់ទីវ ភីភល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍របស់សវនករឯករាជ្យ

## ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

(របាយការណ៍ជាភាសាខ្មែរនេះ ត្រូវបានបកប្រែចេញពីរបាយការណ៍ភាសាអង់គ្លេស។ ប្រសិនបើការបកប្រែ មានភាពខុសគ្នានឹង របាយការណ៍ជាភាសាអង់គ្លេស សូមយករបាយការណ៍ជាភាសាអង់គ្លេសជាគោល។)

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## ព័ត៌មានអំពីក្រុមហ៊ុន

### ក្រុមប្រឹក្សាភិបាល

លោក Tomotaka Inoue

លោក Tatsuhiro Kurihara

លោក Masao Sugita

លោក Yutaka Tanimoto

**ទីស្នាក់ការ:**

អគារលេខ៨៨ ផ្លូវលេខ ២១៤ កែង ១១៣ ភូមិ៤ សង្កាត់ បឹងប្រលឹត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**ធនាគារចំបង:**

ធនាគារ អេស៊ីលីដា ភីអិលស៊ី ,ធនាគារ កម្ពុជាសាធារណៈ ,ធនាគារ កាណាឌីយ៉ា ភីអិលស៊ី , ធនគារ ភ្នំពេញ ពាណិជ្ជ ,ធនាគារឯកទេស វីង (ខេមបូឌា) លីមីតធីត ,ធនាគារជាតិនៃកម្ពុជា

**សវនករ:**

ប៊ី ឌី អូ (ខេមបូឌា) លីមីធីត

លេខចុះបញ្ជីពាណិជ្ជកម្ម:
Co. 0000៩៤២៩

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## មាតិកា


ទំព័រ

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ............ ១ - ៤

របាយការណ៍របស់សវនករឯករាជ្យ ............ ៥ - ៨

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ............ ៩

របាយការណ៍លទ្ធផល ............ ១០

របាយការណ៍ស្តីពីបម្រែបម្រួលមូលធន ............ ១១ - ១២

របាយការណ៍លំហូរសាច់ប្រាក់ ............ ១៣ - ១៤

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ............ ១៥ - ៤២

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសេចក្តីសោមនស្ស សូមដាក់បង្ហាញនូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទគិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

**សកម្មភាពចម្បង**

សកម្មភាពចម្បងរបស់ក្រុមហ៊ុនគឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ។ ពុំមានការផ្លាស់ប្តូរជាសារវន្តសម្រាប់សកម្មភាព អាជីវកម្មចម្បងរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទនេះទេ។

**លទ្ធផលនៃប្រតិបត្តិការ**

| | ២០១៩ | |
|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណេញសម្រាប់ការិយបរិច្ឆេទ | ៥.៤០១.៨១៨ | ២២.០១២.៤១០ |

**ភាគលាភ**

ក្រុមប្រឹក្សាភិបាលពុំបានណែនាំឲ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ។

**ទុនបម្រុង និងសំវិធានធន**

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ។

**ឥណទានអាក្រក់ និង ឥណទានជាប់សង្ស័យ**

នៅមុនពេលដែលរបាយការណ៍លទ្ធផល និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាវិធានការទាក់ទងនឹងការលុបចោលនូវឥណទានអាក្រក់

និងការធ្វើសំវិធានធនចំពោះឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថាឥណទានអាក្រក់ ត្រូវបានជម្រះចេញពីបញ្ជី និងសំវិធានធនគ្រប់គ្រាន់ត្រូវបានធ្វើឡើងសម្រាប់ឥណទានសង្ស័យ។

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាលឱ្យការជម្រះចេញពីបញ្ជីនៃឥណទានអាក្រក់ ឬក៏សំវិធានធនចំពោះឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានភាពមិនគ្រប់គ្រាន់ជាសារវ័ន្តឡើយ។

**ទ្រព្យសកម្ម**

នៅមុនពេលដែលរបាយការណ៍លទ្ធផល និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្តលើកលែងបំណុលចេញដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែងនៅលើទីផ្សារ។

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាល ឲ្យមានការភ័ន្តច្រឡំដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវឡើយ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេក់ទីវ ភីភល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ក្រុមប្រឹក្សាភិបាល (ត)

### វិធីសាស្ត្រកំណត់តម្លៃ

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ដែលបណ្តាលឲ្យមានការភ័ន្តច្រឡំ ឬមានភាពមិនត្រឹមត្រូវដល់វិធីសាស្ត្រកំណត់តម្លៃដែលបានអនុវត្តកន្លងមកលើទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

### បំណុលយថាភាព និងបំណុលផ្សេងៗ

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះពុំមាន ៖

(១)បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាមួយចាប់តាំងពីដំណាច់ឆ្នាំឡើយ ឬ

(២)បំណុលយថាភាពណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងតាំងពីដំណាច់ឆ្នាំនេះឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗដែលត្រូវបានទាមទារឲ្យសងក្នុងរយៈពេល១២ខែបន្ទាប់ពីថ្ងៃដំណាច់ឆ្នាំដែលនឹង ឬអាចមានការប៉ះពាល់ជាសារវ័ន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់កំណត់សងនោះទេ។

### ការផ្លាស់ប្តូរនៃហេតុការណ៍

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើត ឡើងពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលអាចបណ្តាលឲ្យមានចំនួនទឹកប្រាក់ ដែលបានបង្ហាញក្នុងរបាយការណ៍របស់ក្រុមហ៊ុនមានភាពមានកំហុសឆ្គងធ្ងន់ធ្ងរនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុនក្នុងកំឡុងការិយបរិច្ឆេទ នេះមិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្វង់គណនីប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុរហូតមកទល់នឹងថ្ងៃចេញរបាយការណ៍នេះ មិនមានខ្វង់គណនីប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក្នុងកំឡុងការិយបរិច្ឆេទនេះទេ។

## មូលធនភាគហ៊ុន

ក្រុមហ៊ុនមិនបានបោះផ្សាយភាគហ៊ុន នៅក្នុងការិយបរិច្ឆទបច្ចុប្បន្នទេ។

ក្រុមហ៊ុនពុំមានកិច្ចសន្យាផ្តល់ភាគហ៊ុនមិនទាន់បោះផ្សាយ នឹងមិនមានភាគហ៊ុនក្រោមកិច្ចសន្យាផ្តល់សិទ្ធិជាភាគហ៊ុននៃក្រុមហ៊ុននាចុងការិយបរិច្ឆេទនេះទេ។

## សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបម្រើការ ចាប់តាំងពីថ្ងៃចេញរបាយការណ៍ចុងក្រោយមានរាយនាមដូចខាងក្រោម៖

**លោក** Tomotaka Inoue

**លោក** Tatsuhiro Kurihara

**លោក** Masao Sugita

**លោក** Yutaka Tanimoto

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេក់ទីវ ភីភល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ក្រុមប្រឹក្សាភិបាល (ត)

**អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល**

ក្នុងកំឡុងពេល និងចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ក្រុមហ៊ុនមិនបានចូលរួមជាភាគីក្នុងការរៀបចំណាមួយ ក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនឲ្យទទួលបាននូវផលប្រយោជន៍ផ្សេងៗ តាមរយៈការទិញភាគហ៊ុន ឬប័ណ្ណបំណុលពីសាមីក្រុមហ៊ុន ឬក្រុមហ៊ុនផ្សេងទៀតឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃការិយបរិច្ឆេទកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលនូវអត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងរវាងក្រុមហ៊ុន ឬរវាងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏រវាងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវ័ន្តនោះទេ លើកលែងតែចំពោះអត្ថប្រយោជន៍ដែលបានបង្ហាញដូចក្នុងកំណត់សម្គាល់ទី២៧ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

**ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ**

ក្រុមប្រឹក្សាភិបាលមានភារកិច្ចធ្វើការបញ្ជាក់អះអាងថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដើម្បីបង្ហាញ នូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងលទ្ធផលនៃប្រតិបត្តិការព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទនេះ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលត្រូវ ៖

ក. ជ្រើសរើសគោលការណ៍គណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះឱ្យបានជាប់លាប់។

ខ. អនុលោមទៅតាមគោលការណ៍ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម ហៅកាត់ថា ("ស.រ.ហ.អ.ក.ស.ធ.ត.ម") និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញនូវភាពពិត និងត្រឹមត្រូវក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនេះត្រូវបានលាតត្រដាងពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គ. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

ឃ. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្មលើកលែងតែក្នុងករណីសន្មត់យ៉ាងសមរម្យថាក្រុមហ៊ុននឹងមិនអាចបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតដ៏ខ្លីនិង

ង. គ្រប់គ្រង និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព និងចូលរួមក្នុងការសម្រេចចិត្តសំខាន់ៗទាំងអស់ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការ ហើយត្រូវប្រាកដថាការសមេច្រចិត្តលើកិច្ចការទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមនូវរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

**ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីការបញ្ចប់រយៈពេលនៃរបាយការណ៍**

ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីការបញ្ចប់រយៈពេលនៃរបាយការណ៍ត្រូវបានបង្ហាញក្នុង កំណត់សម្គាល់ទី៣១ នៃរបាយការណ៍ហិរញ្ញវត្ថុ។

លេខចុះបញ្ជីពាណិជ្ជកម្ម:
Co. ០០០០៩៤២៩

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេក់ទីវ ភីភល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ក្រុមប្រឹក្សាភិបាល (ត)

### របាយការណ៍ក្រុមប្រឹក្សាភិបាល

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ចាប់ពីទំព័រទី ៩ ដល់ ៤២ ត្រូវបានរៀបចំអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យមនិងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ហើយបង្ហាញនូវទិដ្ឋភាពពិត និងភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទនេះ ។

ចុះហត្ថលេខាជំនួសក្រុមប្រឹក្សាភិបាល

______________________________

**លោក** Tomotaka Inoue

ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ,ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ៣០ មេសា ២០២០

## របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិកនៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

(លេខចុះបញ្ជីពាណិជ្ជកម្ម: Co. ០០០០៩៤២៩)

## សេចក្ដីរាយការណ៍លើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

**មតិយោបល់**

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទគិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ព្រមទាំង របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ ព្រមទាំងកំណត់សម្គាល់ផ្សេងៗ ដែលបានបង្ហាញនៅលើទំព័រទី៩ ដល់ ៤២។

តាមទស្សនៈរបស់យើងខ្ញុំរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងលទ្ធផលនៃប្រតិបត្តិការព្រមទាំងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

**មូលដ្ឋានក្នុងការបញ្ចេញមតិយោបល់**

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs")។ កាតព្វកិច្ចរបស់យើងខ្ញុំបានធ្វើតាមស្តង់ដារ ដោយផ្អែកលើទំនួលខុសត្រូវរបស់សវនករឯករាជ្យទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានភាពគ្រប់

គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់យើងខ្ញុំ។

**ទំនួលខុសត្រូវឯករាជ្យភាព និងក្រមសីលធម៌**

យើងខ្ញុំមានភាពឯករាជ្យពីក្រុមហ៊ុនដោយគោរពទៅតាម ក្រមសីលធម៌របស់គណនេយ្យករជំនាញ និងសវនករ នៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ("Code of Ethic") និងក្រមសីលធម៌របស់គណនេយ្យករជំនាញ ("IESBA Code") របស់ក្រុមប្រឹក្សាភិបាលស្តង់ដារក្រមសីលធម៌អន្តរជាតិសំរាប់គណនេយ្យករជំនាញ ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌ដទៃទៀតទៅតាម ក្រមសីលធម៌របស់គណនេយ្យករជំនាញនេះផងដែរ។

**ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ**

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវនូវព័ត៌មានផ្សេងទៀត។ ព័ត៌មានដែលមានក្នុងរបាយការណ៍របស់ ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍របស់សវនករឯករាជ្យយើងខ្ញុំទេ។ មតិយោបល់របស់យើងខ្ញុំទៅលើ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនបានបង្ហាញក្នុងរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ហើយយើងមិនបានបង្ហាញពីទម្រង់នៃការសន្និដ្ឋានលើការធានាណាមួយឡើយ។

# របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិកនៃ(ត)
# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីតល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

(លេខចុះបញ្ជីពាណិជ្ជកម្ម: Co. ០០០០៩៤២៩)

## សេចក្តីរាយការណ៍លើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ(ត)

**ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ (ត)**

ទាក់ទងជាមួយនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យើងខ្ញុំមានកាតព្វកិច្ចក្នុងការតាមដានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងការអនុវត្ត ពិចារណាថាតើរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលគឺមានភាពជាសារវ័ន្តមិនស្របតាមរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឬការយល់ដឹងរបស់យើងទទួលបានក្នុងសវនកម្ម ឬកំហុសឆ្គងជាសារវ័ន្តត្រូវបានបង្ហាញ។

ប្រសិនបើផ្អែកលើការងារដែលយើងខ្ញុំបានអនុវត្ត យើងខ្ញុំសន្និដ្ឋានថា របាយការណ៍របស់ក្រុមប្រឹក្សាភិបាលមានកំហុសឆ្គងជាសារវ័ន្ត យើងខ្ញុំតម្រូវឱ្យរាយការណ៍ពីការពិត តែយើងមិនមានអ្វីដើម្បីរាយការណ៍ក្នុងរឿងនេះទេ។

**ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ**

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងទទួលខុសត្រូវលើ ការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមិនឱ្យមានការ រាយការណ៍ខុសជាសារវ័ន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលមានភារកិច្ចធ្វើការវាយតម្លៃពីលទ្ធផលនៃសមត្ថ

ភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាព ការលាតត្រដាង ដូចដែលមានបញ្ហាទាក់ទងទៅនឹងការបន្តនិរន្តរភាព និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពគណនេយ្យ លុះត្រាតែក្រុមប្រឹក្សាភិបាលមានបំណងបំលែងជាសាច់ប្រាក់របស់ក្រុមហ៊ុនឬដើម្បីបញ្ឈប់ប្រតិបត្តិការ ឬមិនមានជម្រើសផ្សេងទេដើម្បីធ្វើដូច្នេះបាន។

**ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុ**

គោលបំណងរបស់យើងខ្ញុំគឺដើម្បីទទួលបានអំណះអំណាងយ៉ាងសមហេតុផល ថាតើរបាយការណ៍ហិរញ្ញវត្ថុពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ និងចេញនូវរបាយការណ៍របស់សវនករឯករាជ្យដែលមានការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងយ៉ាងសមហេតុផល គឺជាអំណះអំណាងកម្រិតខ្ពស់ ប៉ុន្តែមិនអាចធានាថាមតិយោបល់របស់សវនកម្មអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា តែងតែការពារនូវកំហុសឆ្គងជាសារវ័ន្ត នៅពេលកើតមានឡើងនោះទេ។ ភាពខុសឆ្គងដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំត្រូវបានពិចារណាថាជាកំហុសឆ្គងជាសារវន្ត ប្រសិនបើជាលក្ខណៈបុគ្គល ឬជាក្រុមពួកគេអាចនឹងត្រូវបានគេរំពឹងថាប្រើបាស្រ់ឥទ្ធិពលសេដ្ឋកិច្ចក្នុងការគ្រប់គ្រងលើការសម្រេចចិត្តរបស់អ្នកប្រើប្រាស់នៅលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិកនៃ(ត)
# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

(លេខចុះបញ្ជីពាណិជ្ជកម្ម: Co. 0000៩៤២៩)

## សេចក្តីរាយការណ៍លើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ(ត)

**ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុ**

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងអនុវត្តការវិនិច្ឆ័យដែលមានជំនាញវិជ្ជាជីវៈ និងរក្សាបាននូវការសង្ស័យដែលមានជំនាញវិជ្ជាជីវៈតាមរយៈការធ្វើសវនកម្ម។ យើងបានធ្វើ៖

- កំណត់ និងការវាយតម្លៃហានិភ័យកំហុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាតើការក្លែងបន្លំ ឬការភ័ន្តច្រឡំ រៀបចំ និងអនុវត្តតាមនីតិវិធីសវនកម្មអាចឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួលបាននូវភស្តុតាងសវនកម្មគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់នូវមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យនៃការមិនរកឃើញកំហុសឆ្គងជាសារវន្ត ជាលទ្ធផលបណ្តាលមកពីការក្លែងបន្លំច្រើនជាងការភ័ន្តច្រឡំ ការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិតគ្នា ការក្លែងបន្លំ ការលុបចោលដោយចេតនា ការបកស្រាយខុស ឬការបដិសេធនៃការត្រួតពិនិត្យផ្ទៃក្នុង។
- ទទួលយកការយល់ដឹងពីការត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅ នឹងការធ្វើសវនកម្មមួយក្នុងគោលបំណង ដើម្បីរៀបចំនីតិវិធីសវនកម្មដែលជាសមរម្យនៅក្នុងកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងនៃការបង្ហាញមតិយោបល់លើប្រសិទ្ធិភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។
- វាយតំលៃនូវភាពសមស្របនៃគោលនយោបាយគណនេយ្យ និងការប៉ាន់ស្មានគណនេយ្យសមហេតុផល និងបង្ហាញការទាក់ទងដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។

- សេចក្តីសន្និដ្ឋានលើភាពសមស្របនៃការគ្រប់គ្រងលើការប្រើប្រាស់មូលដ្ឋាននិរន្តរភាពគណនេយ្យ និងដោយផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើជាភាពជាសារវន្តមិនមានច្បាស់លាស់ ដែលទាក់ទងទៅនឹង ព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចសង្ស័យយ៉ាងខ្លាំងលើសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាព។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាជាភាពជាសារវ័ន្តមិនមានច្បាស់លាស់ យើងខ្ញុំត្រូវបានទាមទារការយកចិត្តទុកដាក់ នៅក្នុងរបាយការណ៍សវនករឯករាជ្យរបស់យើងខ្ញុំ បង្ហាញការទាក់ទងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬបើការបង្ហាញបែបនេះគឺមិនគ្រប់គ្រាន់ដើម្បីកែប្រែមតិយោលបល់របស់យើងខ្ញុំទេ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃការបន្តនិរន្តរភាព របាយការណ៍សវនករ ឯករាជ្យរបស់យើងខ្ញុំ។
- ការវាយតម្លៃលើភាពគ្រប់គ្រាន់នៃការបង្ហាញទាំងឡាយ រចនាសម្ព័ន្ធ និងមាតិកានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមានកំណត់បង្ហាញព័ត៌មាន ថាតើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបង្ហាញពីប្រតិបត្តិការមូលដ្ឋាន និងព្រឹត្តិការណ៍ប្រកបដោយសេចក្តីសម្រេចក្នុងការបង្ហាញនូវភាពត្រឹមត្រូវ។

យើងទាក់ទងជាមួយក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងបញ្ហាដទៃទៀត វិសាលភាពដែលបានគ្រោងទុក និងការកំណត់ពេលវេលានៃការធ្វើសវនកម្ម និងការស្វែងរកការធ្វើសវនកម្មយ៉ាងសំខាន់ រួមបញ្ចូលទាំងកង្វះសំខាន់ណាមួយនៅក្នុងការត្រួតពិនិត្យផ្ទៃក្នុងដែលយើងសម្គាល់ក្នុងកំឡុងពេលធ្វើសវនកម្មរបស់យើងខ្ញុំ។

# របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិកនៃ(ត)
# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

(លេខចុះបញ្ជីពាណិជ្ជកម្ម: Co. 0000៩៤២៩)

## សេចក្តីរាយការណ៍លើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ(ត)

### បញ្ហាផ្សេងៗ

របាយការណ៍នេះត្រូវបានធ្វើឡើង សម្រាប់ភាគហ៊ុនិករបស់ក្រុមហ៊ុនតែប៉ុណ្ណោះ។ យើងខ្ញុំនឹងមិនទទួលខុសត្រូវចំពោះខ្លឹមសារនៃរបាយការណ៍នេះ សម្រាប់បុគ្គលផ្សេងទៀតឡើយ។

**ឃី ភី អឹម ជី (ខេមបូឌា) លីមីធីត**

រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ៣០ មេសា ២០២០

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | កំណត់ សម្គាល់ | ២០១៩ ដុល្លារអាមេរិក | ពាន់រៀល | ២០១៨ ដុល្លារអាមេរិក (កំណត់ឡើងវិញ) |
|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | ៦ | ១៦.៤១៥ | ៦៦.៨៩១ | ៣៣.១១១ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៧ | ៥១១.២៦៤ | ២.០៨៣.៤០១ | ៥០៨.១៣៨ |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ២៣.៧៥៤.៩៤២ | ៩៦.៨០១.៣៨៩ | ៩.០៥៤.៤២៣ |
| ឥណទានទៅអតិថិជន | ៩ | ៦២.៩៩៧.០៨៧ | ២៥៦.៧១៣.១៣០ | ៣៦.៦២៨.២៣៤ |
| គណនីត្រូវទទួលផ្សេងៗ | ១០ | ១.៧២៦.៦២២ | ៧.០៣៥.៩៨៥ | ១.២៣០.៦៨៦ |
| ការវិនិយោគ | ១១ | ៤.២១៧.៦០៨ | ១៧.១៨៦.៧៥៣ | ៤.៣៣០.៤២៧ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១២ | ១.១៣៩.៥៧២ | ៤.៦៤៣.៧៥៦ | ៦៦៦.៤០៧ |
| ទ្រព្យសម្បត្តិអរូបី | ១៣ | ៤៣.០៨០ | ១៧៥.៥៥១ | ៥០.០០១ |
| **ទ្រព្យសកម្មសរុប** | | ៩៤.៤០៦.៥៩០ | ៣៨៤.៧០៦.៨៥៦ | ៥២.៥០១.៤២៧ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេអឹមខេ ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | កំណត់សម្គាល់ | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក (កំណត់ឡើងវិញ) |
|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | ៦ | ១៦.៤១៥ | ៦៦.៨៩១ | ៣៣.១១១ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៧ | ៥១១.២៦៤ | ២.០៨៣.៤០១ | ៥០៨.១៣៨ |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ២៣.៧៥៤.៩៤២ | ៩៦.៨០១.៣៨៩ | ៩.០៥៤.៤២៣ |
| ឥណទានទៅអតិថិជន | ៩ | ៦២.៩៩៧.០៨៧ | ២៥៦.៧១៣.១៣០ | ៣៦.៦២៨.២៣៤ |
| គណនីត្រូវទទួលផ្សេងៗ | ១០ | ១.៧២៦.៦២២ | ៧.០៣៥.៩៨៥ | ១.២៣០.៦៨៦ |
| ការវិនិយោគ | ១១ | ៤.២១៧.៦០៨ | ១៧.១៨៦.៧៥៣ | ៤.៣៣០.៤២៧ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១២ | ១.១៣៩.៥៧២ | ៤.៦៤៣.៧៥៦ | ៦៦៦.៤០៧ |
| ទ្រព្យសម្បត្តិអរូបី | ១៣ | ៤៣.០៨០ | ១៧៥.៥៥១ | ៥០.០០១ |
| **ទ្រព្យសកម្មសរុប** | | ៩៤.៤០៦.៥៩០ | ៣៨៤.៧០៦.៨៥៦ | ៥២.៥០១.៤២៧ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។

លេខចុះបញ្ជីពាណិជ្ជកម្ម:
Co. 0000៩៤២៩

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេក់ទីវ ភីភល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លទ្ធផល

សម្រាប់ការិយបរិច្ឆេទឆ្នាំ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩

| | កំណត់សម្គាល់ | | ពាន់រៀល | ២០១៨ ដុល្លារអាមេរិក (កំណត់ឡើងវិញ) |
|---|---|---|---|---|
| ទចំណូលការប្រាក់ | ១៩ | ៨.២៨៨.១៧២ | ៣៣.៧៧៤.៣០១ | ៤.៨២៩.៨៧២ |
| ចំណាយការប្រាក់ | ២០ | (២.៥១២.០៦៩) | (១០.២៣៦.៦៨១) | (១.៤៣៣.៥១១) |
| ចំណូលការប្រាក់សុទ្ធ | | ៥.៧៧៦.១០៣ | ២៣.៥៣៧.៦២០ | ៣.៣៩៦.៣៦១ |
| សំវិធានធនលើឥណទានជាប់សង្ស័យ | ៩ | (២.១៨៧.៨៧៣) | (៨.៩១៥.៥៨២) | (១.៣៥០.៤៦៦) |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២១ | ៩.១០៩.៦៩៦ | ៣៧.១២២.០១២ | ៥.៣៦៧.៥៣៧ |
| ចំណាយប្រាក់បៀវត្ស | ២២ | (៣.១៨៤.៧៩៩) | (១២.៩៧៨.០៥៦) | (១.៧៥២.៣៤៣) |
| ចំណាយរំលស់ | ២៣ | (២៦៨.២៩០) | (១.០៩៣.២៨២) | (១៦៤.០៥៨) |
| ចំណាយទូទៅ និងរដ្ឋបាល | ២៤ | (២.៤២៩.៤៤០) | (៩.៨៩៩.៩៦៨) | (១.៦៤៩.៦៦៥) |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។



| | | | | |
|---|---|---|---|---|
| ចំណេញមុនបង់ពន្ធ | | ៦.៨១៥.៣៩៧ | ២៧.៧៧២.៧៤៤ | ៣.៨៤៧.៣៦៦ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៥ | (១.៤១៣.៥៧៩) | (៥.៧៦០.៣៣៤) | (៨២៧.៧១២) |
| ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ | | ៥.៤០១.៨១៨ | ២២.០១២.៤១០ | ៣.០១៩.៦៥៤ |
| ចំណូលផ្សេងៗ បន្ទាប់ពីគិតពន្ធរួច | | - | - | - |
| ចំណូលផ្សេងៗសរុបក្នុងការិយបរិច្ឆេទ | | ៥.៤០១.៨១៨ | ២២.០១២.៤១០ | ៣.០១៩.៦៥៤ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេក់ទីវ ភីភល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | កំណត់សម្គាល់ | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក (កំណត់ឡើងវិញ) |
|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ចំណេញមុនដកចំណាយពន្ធ | | ៦.៨១៥.៣៩៧ | ២៧.៧៧២.៧៤៤ | ៣.៨៤៧.៣៦៧ |
| និយ័តកម្ម៖ | | | | |
| សំវិធានធនសម្រាប់ឥណទានសង្ស័យ | ៩(ក) | ២.១៨៧.៨៧៣ | ៨.៩១៥.៥៨២ | ១.៣៥០.៤៦៦ |
| រំលស់ទ្រព្យសម្បត្តិអរូបី | ១៣ | ១២.៤៣៧ | ៥០.៦៨១ | ៨.៥១៥ |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ១២ | ២៥៥.៨៥៣ | ១.០៤២.៦០១ | ១៥៥.៥៤២ |
| ចំណូលភាគលាភ | | (១១.៧២៩) | (៤៧.៧៩៦) | (១៥.៧៧២) |
| ខាត/(ចំណេញ)នៃតម្លៃទីផ្សារលើការវិនិយោគ | | ១១២.៨១៩ | ៤៥៩.៧៣៧ | (២៨.២៥៤) |
| ចំណាយការប្រាក់ | ២០ | ២.៥១២.០៦៩ | ១០.២៣៦.៦៨១ | ១.៤៣៣.៥១១ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។

| | | | | |
|---|---|---|---|---|
| ចំណេញមុនពេលបម្រែបម្រួល | | | | |
| ដើមទុនបង្វិល | | ១១.៨៨៤.៧១៩ | ៤៨.៤៣០.២៣០ | ៦.៧៥១.៣៧៥ |
| បម្រែបម្រួលដើមទុនបង្វិលៈ | | | | |
| ឥណទានទៅអតិថិជន | | (២៨.៥៥៦.៧២៦) | (១១៦.៣៦៨.៦៥៨) | (១១.១៩១.៧២៣) |
| គណនីត្រូវទទួលផ្សេងៗ | | (៤៩៥.៩៣៦) | (២.០២០.៩៣៩) | ៤១១.៦១៤ |
| គណនីត្រូវបង់ផ្សេងៗ | | ៩៧៦.៧៩៥ | ៣.៩៨០.៤៤០ | (៧៧.៣៦៧) |
| សាច់ប្រាក់ប្រើក្នុងសកម្មភាពប្រតិបត្តិការ | | (១៦.១៩១.១៤៨) | (៦៥.៩៧៨.៩២៧) | (៤.១០៦.១០១) |
| ពន្ធដែលបានបង់ | | (៨៨៥.២២៩) | (៣.៦០៧.៣០៨) | (២៦៨.៧៦២) |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពប្រតិបត្តិការ | | (១៧.០៧៦.៣៧៧) | (៦៩.៥៨៦.២៣៥) | |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ភាគលាភទទួលបាន | | ១១.៧២៩ | ៤៧.៧៩៦ | ១៥.៧៧២ |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ១២ | (៧២៩.០១៨) | (២.៩៧០.៧៤៨) | (៣១៤.៤៩៨) |
| ការទិញទ្រព្យសម្បត្តិអរូបី | ១៣ | (៥.៥១៦) | (២២.៤៧៨) | (៣៤.៣១២) |
| ការទិញការវិនិយោគ | ១១ | - | - | (៣.៣០០.០០០) |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | | (៧២២.៨០៥) | (២.៩៤៥.៤៣០) | (៣.៦៣៣.០៣៨) |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់ (ត)

សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | កំណត់សម្គាល់ | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក (កំណត់ឡើងវិញ) |
|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់ទទួលបានពីអនុបំណុល | ១៧ | ៩.៩៩៨.២០០ | ៤០.៧៤២.៦៦៤ | - |
| សាច់ប្រាក់ទទួលបានពីកម្ចី | | ២៥.០០០.០០០ | ១០១.៨៧៥.០០០ | ១៣.៩៥០.០០០ |
| ចំណាយការប្រាក់ | | (២.៥១២.០៦៩) | (១០.២៣៦.៦៨១) | (១.៤៣៣.៥១១) |
| សាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញប្បទាន | | ៣២.៤៨៦.១៣១ | ១៣២.៣៨០.៩៨៣ | ១២.៥១៦.៤៨៩ |
| **កំណើន នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | ១៤.៦៨៦.៩៤៩ | ៥៩.៨៤៩.៣១៨ | ៤.៥០៨.៥៨៨ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមគ្រា** | | ៩.០៩៥.៥៨២ | ៣៧.០៦៤.៤៩៦ | ៤.៥៨៦.៩៩៤ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងគ្រា** | | ២៣.៧៨២.៥៣១ | ៩៦.៩១៣.៨១៤ | ៩.០៩៥.៥៨២ |

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។

| | កំណត់ សម្គាល់ | ២០១៩ ដុល្លារអាមេរិក | ពាន់រៀល | ២០១៨ ដុល្លារអាមេរិក (កំណត់ឡើងវិញ) |
|---|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ៦ | ១៦.៤១៥ | ៦៦.៨៩១ | ៣៣.១១១ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា (មិនរួមបញ្ចូលប្រាក់តម្កល់) | ៧ | ១១.១៧៤ | ៤៥.៥៣៤ | ៨.០៤៨ |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ២៣.៧៥៤.៩៤២ | ៩៦.៨០១.៣៨៩ | ៩.០៥៤.៤២៣ |
| | | ២៣.៧៨២.៥៣១ | ៩៦.៩១៣.៨១៤ | ៩.០៩៥.៥៨២ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។

